ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ឯកសារជំនួយស្មារតី

## សម្រាប់

## ការពិនិត្យបញ្ជីឈ្មោះ

## និងការចុះឈ្មោះបោះឆ្នោត

## ឆ្នាំ២០១៩

# មាតិកា


**គោលបំណង** ........ ១

I. **ការិយាល័យបោះឆ្នោត និងការិយាល័យចុះឈ្មោះបោះឆ្នោត** ........ ២

១. ការិយាល័យបោះឆ្នោត ........ ២

២. ការិយាល័យចុះឈ្មោះបោះឆ្នោត ........ ២

ក. ទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត ........ ២

ខ. បរិវេណខាងក្នុង និងបរិវេណខាងក្រៅនៃការិយាល័យចុះឈ្មោះបោះឆ្នោត (ក្រៅពីសាលាឃុំ សង្កាត់) ........ ២

គ. គំនូសតាងស្ដីពីរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ........ ៣

៣. ការបិទ និងការផ្សព្វផ្សាយបញ្ជី និងឯកសារនានាទាក់ទងនឹងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ... ៣

ក. ការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត ........ ៣

ខ. ការបិទផ្សាយបញ្ជីបោះឆ្នោតចុងក្រោយ ........ ៣

គ. ការផ្សព្វផ្សាយអំពីរយៈពេល កាលបរិច្ឆេទ និងប្រតិទិននៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ... ៣

៤. ការទទួលខុសត្រូវលើការងារសន្តិសុខសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ........ ៤

II. **ក្រុមចុះឈ្មោះបោះឆ្នោត** (**ក.ច.ប**) ........ ៤

១. សមាសភាព ក.ច.ប ........ ៤

២. តួនាទី និងភារកិច្ចរបស់ ក.ច.ប ........ ៤

III. **សម្ភារ ឯកសារសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត** ........ ៥

១. សម្ភារ បរិក្ខារកុំព្យូទ័រ និងឯកសារបម្រើការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៩ ........ ៥

២. របៀបថែរក្សាសម្ភារ បរិក្ខារកុំព្យូទ័រ ........ ៥

IV. **ភាពមានសិទ្ធិចុះឈ្មោះបោះឆ្នោត** ........ ៦

១. លក្ខខណ្ឌដើម្បីមានសិទ្ធិចុះឈ្មោះបោះឆ្នោត ........ ៦

២. លក្ខខណ្ឌដើម្បីចុះឈ្មោះបោះឆ្នោត ........ ៧

៣. ឯកសារសម្រាប់ប្រើប្រាស់ក្នុងការសុំចុះឈ្មោះបោះឆ្នោត ........ ៧

ក. ឯកសារដែលអ្នកសុំចុះឈ្មោះបោះឆ្នោតត្រូវបង្ហាញ ក.ច.ប ដើម្បីសុំចុះឈ្មោះបោះឆ្នោត ........ ៧

ខ. សាក្សី និងឯកសារសម្រាប់ការស្នើសុំ ឯ.អ ........ ៧

គ. សាក្សី និងឯកសារសម្រាប់ការស្នើសុំលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ ........ ៨

V. **ដំណើរប្រព្រឹត្តទៅនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត** ........ ៨

១. ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៩ ........ ៨
២. ជំហានទាំង ៤ នៃការចុះឈ្មោះបោះឆ្នោត ........ ៩
៣. ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត តាមករណីនីមួយៗ ........ ៩
ក. ករណីពុំមាន អ.ខ ឬមាន អ.ខ ប៉ុន្តែពុំមានលក្ខខណ្ឌគ្រប់គ្រាន់ ........ ៩
ខ. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតបានចុះឈ្មោះបោះឆ្នោតរួចហើយ ប៉ុន្តែឈ្មោះ ឬ/និងទិន្នន័យក្នុងបញ្ជីបោះឆ្នោតកត់ត្រាមិនត្រឹមត្រូវ ........ ១០
គ. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមាន អ.ខ ឬ ឯ.អ និងធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយ ........ ១២
ឃ. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតបានចុះឈ្មោះរួចហើយឆ្នាំ២០១៨ ក្នុងឃុំ សង្កាត់ផ្សេង ........ ១៣
ង. ករណីអ្នកសុំចុះឈ្មោះបានចុះឈ្មោះបោះឆ្នោតរួចហើយនៅឃុំ សង្កាត់ផ្សេងក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ........ ១៥
ច. ករណីអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត បានទទួលមរណភាពក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងការចុះឈ្មោះបោះឆ្នោត ........ ១៥
៤. ការពិនិត្យ និងសម្រេចរបស់ ក.ច.ប លើរបាយការណ៍ស្តីពីការស្រង់ឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត ........ ១៥
VI. **គំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងក្នុងដំណាក់កាលនៃការចុះឈ្មោះបោះឆ្នោត** ........ ១៦
VII. **ការប្រើប្រាស់ទម្រង់បែបបទ** ........ ១៧
VIII. **ការវេចខ្ចប់កញ្ចប់ «ក» ដាក់ក្នុងស្បោង «ខ» ដើម្បីបញ្ជូន និងប្រគល់ជូន លធ.ខប** ... ៣៤
១. ការវេចខ្ចប់កញ្ចប់ «ក» តាមការិយាល័យបោះឆ្នោតនីមួយៗ ........ ៣៤
២. ការវេចខ្ចប់កញ្ចប់ដាក់គល់សន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោតដែលបានប្រើហើយ និងនៅសល់មិនទាន់ប្រើសរុបក្នុងឃុំ សង្កាត់ ........ ៣៤
ក. ការវេចខ្ចប់កញ្ចប់ដាក់គល់សន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ដែលបានប្រើហើយសរុបក្នុងឃុំ សង្កាត់ ........ ៣៥
ខ. ការវេចខ្ចប់កញ្ចប់ដាក់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ដែលនៅសល់មិនទាន់ប្រើសរុបក្នុងឃុំ សង្កាត់ ........ ៣៥
៣. ការវេចខ្ចប់សម្ភារ ឯកសារដាក់ក្នុងស្បោង «ខ» បញ្ជូនទៅ លធ.ខប ........ ៣៦
ក. ការវេចខ្ចប់ស្បោង «ខ» ទី១ ........ ៣៦
ខ. ការវេចខ្ចប់ស្បោង «ខ» ទី២ និងស្បោង «ខ» បន្តបន្ទាប់ ........ ៣៧

៤. ការបញ្ជូនស្បោង «ខ» ទៅ លធ.ខប ............................................................ ៣៨

៥. ការត្រួតពិនិត្យស្បោង «ខ» នៅ លធ.ខប និងការវេចខ្ចប់ស្បោង «ខ» ដាក់ក្នុងស្បោង «គ» បញ្ជូនមកនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត ............................................................ ៣៨

ក. ការត្រួតពិនិត្យស្បោង «ខ» នៅ លធ.ខប ............................................................ ៣៨

ខ. ការវេចខ្ចប់ស្បោង «គ» បញ្ជូនទៅនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត............ ៤០

៦. ការវេចខ្ចប់សម្ភារ ឯកសារផ្សេងៗទៀតដែលបានផ្គត់ផ្គង់បម្រើឱ្យការចុះឈ្មោះបោះឆ្នោតបញ្ជូនមក គ.ជ.ប....... ៤១

**IX. ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូងជាសាធារណៈសម្រាប់គោលដៅនៃការប្ដឹងតវ៉ា ឬ/និងការប្ដឹងជំទាស់** ............................................................ ៤១

១. ទីកន្លែងផ្សព្វផ្សាយបញ្ជីបោះឆ្នោតដំបូង ............................................................ ៤១

២. កាលបរិច្ឆេទនៃការផ្សព្វផ្សាយបញ្ជីបោះឆ្នោតដំបូង ............................................................ ៤២

**X. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង** ............................................................ ៤២

១. គំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងក្នុងដំណាក់កាលនៃការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៩ ............................. ៤៣

ក. ករណីពាក្យបណ្ដឹងតវ៉ា............................................................ ៤៣

ខ. ករណីពាក្យបណ្ដឹងជំទាស់ ............................................................ ៤៤

២. ការរៀបចំបញ្ជីបោះឆ្នោតផ្លូវការ ............................................................ ៤៥

# អក្សរកាត់

| | | |
|---|---|---|
| ១. | គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | គ.ជ.ប |
| ២. | លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត | លធ.ខប |
| ៣. | ក្រុមប្រឹក្សាឃុំ សង្កាត់ | កបឃ.ស |
| ៤. | ក្រុមចុះឈ្មោះបោះឆ្នោត | ក.ច.ប |
| ៥. | ក្រុមចុះឈ្មោះបោះឆ្នោតពិសេស | ក.ច.ប.ព |
| ៦. | ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ | ច.ប.ត.រ |
| ៧. | បទបញ្ជា និងនីតិវិធី សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ | ប.ន.ព.ច |
| ៨. | អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | អ.ខ |
| ៩. | ឯកសារបញ្ជាក់អត្តសញ្ញាណ | ឯ.អ |
| ១០. | នាយកដ្ឋាន | ន. |
| ១១. | នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត | ន.គ.ទ.ប |
| ១២. | ទម្រង់បែបបទលេខ | ទ. |

# គោលបំណង

ឯកសារជំនួយស្មារតីនេះបានដកស្រង់យកនូវចំណុចគន្លឹះសំខាន់ៗតាមលំដាប់លំដោយពីបទបញ្ជា និងនីតិវិធី និងសៀវភៅណែនាំសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ដែលនឹងត្រូវចាប់ផ្តើមពីថ្ងៃទី ១ ដល់ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៩ ខាងមុខនេះ។

ឯកសារជំនួយស្មារតីនេះមានគោលបំណងពន្យល់អំពីនីតិវិធី បច្ចេកទេសបទប្បញ្ញត្តិ និងគោលការណ៍សំខាន់ៗនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមប្រព័ន្ធកុំព្យូទ័រ ដើម្បីឱ្យមន្ត្រីបោះឆ្នោត ជាពិសេស ក.ច.ប និង កបឃ.ស ទាំងអស់សិក្សាស្វែងយល់ និងអនុវត្តការងារតាមតួនាទី និងភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ ទាន់ពេលវេលា និងប្រកបដោយលទ្ធផលល្អ។

ឯកសារជំនួយស្មារតីនេះក៏ជាជំនួយដ៏សំខាន់សម្រាប់គណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល អ្នកសង្កេតការណ៍បោះឆ្នោត និងស្ថាប័នពាក់ព័ន្ធទាំងអស់ ដើម្បីសិក្សាស្វែងយល់ និងរួមសហការអនុវត្តតាមតួនាទីភារកិច្ចរបស់ខ្លួន ដើម្បីឱ្យការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៩ នេះប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងតម្លាភាព។

# ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៩

## I. ការិយាល័យបោះឆ្នោត និងការិយាល័យចុះឈ្មោះបោះឆ្នោត

ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៩ មានរយៈពេល ២២ថ្ងៃ ដោយត្រូវចាប់ផ្តើមពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៩ រួចបញ្ចប់នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ ២០១៩។

### ១. ការិយាល័យបោះឆ្នោត

ការិយាល័យបោះឆ្នោតនីមួយៗ ត្រូវមានប្រជាពលរដ្ឋដែលមានឈ្មោះបោះឆ្នោតយ៉ាងច្រើន ៧៥០នាក់។ ក្នុងករណីការិយាល័យបោះឆ្នោតណាមួយ មានចំនួនអ្នកបោះឆ្នោតលើសពី ៧៥០នាក់ គ.ជ.ប ត្រូវបញ្ចូលឈ្មោះអ្នកដែលលើសនោះទៅក្នុង៖

ក) ការិយាល័យបោះឆ្នោតណាមួយក្នុងភូមិជាមួយ ឬ

ខ) ការិយាល័យបោះឆ្នោតណាដែលជិតបំផុតនៅក្នុងឃុំ សង្កាត់ ឬ

គ) ការិយាល័យដែលបង្កើតថ្មីក្នុងភូមិជាមួយ។

### ២. ការិយាល័យចុះឈ្មោះបោះឆ្នោត

#### ក. ទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត

ជាគោលការណ៍ ការិយាល័យចុះឈ្មោះបោះឆ្នោតត្រូវមាននៅ ២ទីតាំង គឺ៖

- **នៅសាលាឃុំ សង្កាត់៖** ជាការិយាល័យចុះឈ្មោះបោះឆ្នោតចម្បង ដែលបើកបម្រើការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ នៅពេលចាប់ផ្តើម និងពេលបញ្ចប់ ដោយប្រើរយៈពេលប្រមាណពាក់កណ្តាលនៃរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតសរុប។
- **នៅតាមទួមិមួយចំនួនក្នុងឃុំ សង្កាត់៖** ត្រូវបើកបម្រើការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ដោយប្រើពេលវេលាសរុប មិនឱ្យលើសពីពាក់កណ្តាលនៃរយៈពេលរួមដែលបានកំណត់ឡើយ។

ការិយាល័យចុះឈ្មោះបោះឆ្នោតនីមួយៗ ត្រូវបើកបម្រើការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត សម្រាប់ប្រជាពលរដ្ឋដែលមានសិទ្ធិចុះឈ្មោះបោះឆ្នោត មកពីគ្រប់ភូមិ ក្នុងព្រំប្រទល់ឃុំ សង្កាត់។

#### ខ. បរិវេណខាងក្នុង និងបរិវេណខាងក្រៅនៃការិយាល័យចុះឈ្មោះបោះឆ្នោត (ក្រៅពីសាលាឃុំ សង្កាត់)




- **បរិវេណខាងក្នុង** មានកាំប្រវែងយ៉ាងតិច ១៥ម៉ែត្រ។
- **បរិវេណខាងក្រៅ** មានកាំប្រវែង ១០០ម៉ែត្រ ឬតូចជាងអាស្រ័យដោយស្ថានភាពទីតាំងជាក់ស្តែង ឬមានទម្រង់ផ្សេងពីនេះ។

គ. គំនូសតាងស្ដីពីរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត

ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៩ អាចបែងចែកពេលវេលាទៅតាមគំនូសតាង ដូចខាងក្រោម៖




៣. ការបិទ និងការផ្សព្វផ្សាយបញ្ជី និងឯកសារនានាទាក់ទងនឹងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត

ក. ការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត

កបឃ.ស ត្រូវបិទផ្សាយជាសាធារណៈនូវបញ្ជីឈ្មោះទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត ដូចខាងក្រោម៖

- ទីតាំងបិទផ្សាយ៖ ១) នៅសាលាឃុំ សង្កាត់ និង
  ២) នៅទីតាំងមួយចំនួនក្នុងឃុំ សង្កាត់
- កាលបរិច្ឆេទបិទផ្សាយ៖ យ៉ាងយូរនៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៩។

ខ. ការបិទផ្សាយបញ្ជីបោះឆ្នោតចុងក្រោយ

កបឃ.ស ត្រូវបិទផ្សាយបញ្ជីបោះឆ្នោតឆ្នាំ២០១៨ ដែល គ.ជ.ប ផ្ដល់សុពលភាពចុងក្រោយ ដូចខាងក្រោម៖

- ទីតាំងបិទផ្សាយ៖ ១) នៅសាលាឃុំ សង្កាត់ និង
  ២) នៅទីប្រជុំជនក្នុងឃុំ សង្កាត់
- កាលបរិច្ឆេទបិទផ្សាយ៖ យ៉ាងយូរនៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៩។

**ចំណាំ៖** បញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៨ ចំនួន ១ច្បាប់ ទុកសម្រាប់ ក.ច.ប ប្រើប្រាស់នៅពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត។

គ. ការផ្សព្វផ្សាយអំពីរយៈពេល កាលបរិច្ឆេទ និងប្រតិទិននៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត

កបឃ.ស និងប្រធាន ក.ច.ប ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈអំពីរយៈពេល កាលបរិច្ឆេទ និងប្រតិទិននៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់របស់ខ្លួន ក្នុងរយៈពេល**យ៉ាងតិច ៣ថ្ងៃ**មុនពេលចាប់ផ្ដើមធ្វើការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

### ៤. ការទទួលខុសត្រូវលើការងារសន្តិសុខសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត

កបឃ.ស ត្រូវចាត់ចែងតាមលទ្ធភាព និងការចាំបាច់ឱ្យមានកម្លាំងរក្សាសណ្តាប់ធ្នាប់ដែលមានភារកិច្ចដូចខាងក្រោម៖

- សម្រួលសណ្តាប់ធ្នាប់ សម្រាប់ប្រជាពលរដ្ឋដែលចូលមកកាន់ការិយាល័យចុះឈ្មោះបោះឆ្នោត ដើម្បីសុំចុះឈ្មោះបោះឆ្នោត
- សម្រួលអនុញ្ញាតឱ្យចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោតម្តង ៣នាក់
- ផ្តល់អាទិភាពចំពោះព្រះសង្ឃ ជនចាស់ជរា ស្រ្តីមានផ្ទៃពោះ ស្រ្តីមានកូនតូច អ្នកមានជំងឺ និងជនដែលមានពិការភាព ចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត
- អនុញ្ញាតឱ្យអ្នកជំនួយជានីតិជនម្នាក់ ជូនដំណើរជនដែលមានពិការភាពដែលមិនអាចចុះឈ្មោះបោះឆ្នោតដោយខ្លួនឯងបាន ចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត
- ថែរក្សាសុវត្ថិភាព និងសន្តិសុខ ដើម្បីបង្ការការបាត់បង់សម្ភារ បរិក្ខារនានាបម្រើឱ្យការចុះឈ្មោះបោះឆ្នោត (ប្រសិនបើសម្ភារ បរិក្ខារទាំងនោះរក្សាទុកនៅសាលាឃុំ សង្កាត់)
- រាយការណ៍ជាបន្ទាន់ជូន កបឃ.ស ក្នុងករណីមានការអុកឡុករំខានពីជនណាម្នាក់ ឬច្រើននាក់ ដើម្បីមានវិធានការស្នើសុំអន្តរាគមន៍ពីភ្នាក់ងារសន្តិសុខ ឬ/និងអាជ្ញាធរមានសមត្ថកិច្ច។

## II. ក្រុមចុះឈ្មោះបោះឆ្នោត (ក.ច.ប)

### ១. សមាសភាព ក.ច.ប

ឃុំ សង្កាត់នីមួយៗត្រូវមាន ក.ច.ប មួយដែលមាន៖

- ប្រធាន ១រូប (ជ្រើសរើសដោយ គ.ជ.ប)
- អនុប្រធាន ១រូប (ជាស្មៀនឃុំ សង្កាត់សាមី)
- ការីកុំព្យូទ័រ ១រូប (ជ្រើសរើសដោយ គ.ជ.ប)

### ២. តួនាទី និងភារកិច្ចរបស់ ក.ច.ប

ក.ច.ប ជាមន្ត្រីចុះឈ្មោះបោះឆ្នោត ដែលមានភារកិច្ចសំខាន់ៗ ដូចខាងក្រោម៖

- គោរព ច.ប.ត.រ ប.ន.ព.ច និងមានជំហរឯករាជ អព្យាក្រឹត និងមិនលម្អៀង
- ចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- យល់ដឹងច្បាស់ និងម្ចាស់ការលើរាល់នីតិវិធីពាក់ព័ន្ធនឹងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- ចាត់វិធានការចាំបាច់នានា ដើម្បីធានាឱ្យជនគ្រប់រូបបានចូលរួមប្រកបដោយសុវត្ថិភាព គ្មានការភ័យខ្លាច គ្មានការបំភិតបំភ័យក្នុងដំណើរការពិនិត្យបញ្ជីឈ្មោះ

និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលខ្លួនទទួលខុសត្រូវ សំដៅធ្វើឱ្យដំណើរការនេះប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងមានតម្លាភាព
- បំពេញទម្រង់បែបបទពាក់ព័ន្ធផ្សេងៗដែលបានកំណត់ ចេះធ្វើកុំព្យូទ័រកម្មទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោត និងចេះធ្វើរបាយការណ៍បានច្បាស់លាស់
- អនុវត្តតាមសេចក្តីសម្រេចរបស់ កបឃ.ស ឬ គ.ជ.ប ឬក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងការចុះឈ្មោះបោះឆ្នោតជូនអ្នកសុំចុះឈ្មោះបោះឆ្នោត
- សហការជាមួយ លធ.ខប ដើម្បីអនុវត្តនីតិវិធីលុបឈ្មោះអ្នកដែលទទួលមរណភាព អ្នកដែលត្រូវបានដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត អ្នកដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត និងអ្នកដែលបានផ្លាស់ លំនៅឋាន ឬទីសំណាក់ចេញទៅឃុំ សង្កាត់ផ្សេង ឬ សហការជាមួយ លធ.ខប និង កបឃ.ស ដើម្បីជូនដំណឹងដល់អ្នកមិនទាន់បានចុះឈ្មោះបោះឆ្នោតពីមុនមក អ្នកទើបគ្រប់អាយុចុះឈ្មោះបោះឆ្នោត និងអ្នកដែលបានផ្លាស់លំនៅឋាន ឬទីសំណាក់ចូលថ្មី ឱ្យមកបំពេញលក្ខខណ្ឌចុះឈ្មោះបោះឆ្នោត
- រក្សាការសម្ងាត់នៃព័ត៌មានរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត ដែលទទួលបានក្នុងដំណើរការនៃការចុះឈ្មោះបោះឆ្នោត។

## III. សម្ភារ ឯកសារសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត

### ១. សម្ភារ បរិក្ខារកុំព្យូទ័រ និងឯកសារបម្រើការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៩

សម្ភារ បរិក្ខារកុំព្យូទ័រសំខាន់ៗ សម្រាប់បម្រើការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៩ តាមប្រព័ន្ធកុំព្យូទ័រ មានសរុប ១៣មុខ (ដូចមានរាយនាមក្នុងសៀវភៅណែនាំ)។

ទម្រង់បែបបទដែលមានគំរូស្រាប់ សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត មានសរុប ២០មុខ។

### ២. របៀបថែរក្សាសម្ភារ បរិក្ខារកុំព្យូទ័រ

ក្រោយបញ្ចប់ការចុះឈ្មោះបោះឆ្នោតប្រចាំថ្ងៃ ក.ច.ប ត្រូវរៀបចំដាក់សម្ភារ បរិក្ខារកុំព្យូទ័រទាំងអស់ចូលក្នុងកេស ដើម្បីរក្សាទុកឱ្យបានត្រឹមត្រូវ តាមការណែនាំដូចខាងក្រោម៖

- ☛ សម្ភារ បរិក្ខារដែលងាយនឹងបាក់បែក ដូចជាកុំព្យូទ័រយួរដៃ អេក្រង់កុំព្យូទ័រទី២ កាមេរ៉ា ម៉ាស៊ីនផ្តិតស្នាមម្រាមដៃ ត្រូវដាក់ចូលក្នុងកាតាប។
- ☛ សម្ភារ បរិក្ខារតូចៗណាដែលងាយបាត់ ដូចជា USB Flash, Modem, Sim Card, SD Card, Mouse, ... ត្រូវដាក់ចូលក្នុងកាបូប ឬកាតាប។
- ☛ សម្ភារ បរិក្ខារណាដែលធ្ងន់ៗ ត្រូវដាក់នៅខាងក្រោម រីឯសម្ភារ បរិក្ខារណាដែលស្រាលៗ ត្រូវដាក់នៅពីលើ។

- ត្រូវរៀបចំទុកដាក់សម្ភារ បរិក្ខារសម្រាប់ការចុះឈ្មោះបោះឆ្នោតទាំងអស់ ចូលទៅក្នុងកេសស័ង្កសី រួចចាក់សោ និងរក្សាទុកនៅកន្លែងណាដែលមានសីតុណ្ហ-ភាពត្រជាក់ល្មម ស្ងួត និងមានសុវត្ថិភាព។
- ត្រូវផ្ទៀងផ្ទាត់ឱ្យប្រាកដថា សម្ភារ ឯកសារ និងបរិក្ខារទាំងអស់មានគ្រប់មុខ មុនពេលចាកចេញពីការិយាល័យចុះឈ្មោះបោះឆ្នោត។
- ត្រូវយកកុំព្យូទ័រយួរដៃ និង Power Bank ទៅសាកថ្មឱ្យបានពេញនៅពេលល្ងាច ក្រោយចប់ការចុះឈ្មោះបោះឆ្នោតប្រចាំថ្ងៃ ដើម្បីឱ្យមានថាមពលអគ្គិសនីពេញសម្រាប់បន្តការចុះឈ្មោះបោះឆ្នោតនៅថ្ងៃស្អែកទៀត សម្រាប់ឃុំ សង្កាត់ណាដែលពុំមានថាមពលអគ្គិសនីគ្រប់គ្រាន់។

## IV. ភាពមានសិទ្ធិចុះឈ្មោះបោះឆ្នោត

ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត គ.ជ.ប នឹងជួបៈ

- **អ្នកមកសុំចុះឈ្មោះបោះឆ្នោត ដែលជាៈ**
  - ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលមិនទាន់បានចុះឈ្មោះបោះឆ្នោត
  - ប្រជាពលរដ្ឋខ្មែររស់នៅក្នុងឃុំ សង្កាត់ ដែលទើបគ្រប់អាយុ ១៨ឆ្នាំឡើងគិតដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ (កើតមុន ឬត្រឹមថ្ងៃទី០១ ខែសីហា ឆ្នាំ២០០១)
  - ប្រជាពលរដ្ឋខ្មែរដែលបានផ្លាស់លំនៅឋាន ឬទីសំណាក់ចូលក្នុងឃុំ សង្កាត់ថ្មី។
- **អ្នកមកស្នើសុំធ្វើបច្ចុប្បន្នភាព ដែលជាៈ**
  - ប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ឆ្នាំ២០១៨ រួចហើយ ប៉ុន្តែឈ្មោះ ឬ/និងទិន្នន័យក្នុងបញ្ជីបោះឆ្នោតកត់ត្រាមិនត្រឹមត្រូវ
  - ប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ឆ្នាំ២០១៨ រួចហើយ ប៉ុន្តែស្នើសុំប្តូរការិយាល័យពីភូមិមួយទៅភូមិមួយទៀតក្នុងឃុំ សង្កាត់ដដែល ឬសុំប្តូរពីការិយាល័យមួយទៅការិយាល័យមួយទៀតក្នុងភូមិតែមួយ
  - ប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ឆ្នាំ២០១៨ ដែលបានទទួលមរណ-ភាព ហើយត្រូវបានសមាជិកគ្រួសាររាយការណ៍ផ្ទាល់ជូន គ.ជ.ប ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

### ១. លក្ខខណ្ឌដើម្បីមានសិទ្ធិចុះឈ្មោះបោះឆ្នោត

ដើម្បីមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប្រជាពលរដ្ឋត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោមៈ

- មានសញ្ជាតិខ្មែរ
- មានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ គិតដល់ថ្ងៃ៣១ ខែកក្កដា ឆ្នាំ២០១៩
- មានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវចុះឈ្មោះបោះឆ្នោត
- មិនត្រូវស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ឬមិនត្រូវបានដកសិទ្ធិបោះឆ្នោត
- ពុំមែនជាជនវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាលទូទៅ ដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច។

## ២. លក្ខខណ្ឌដើម្បីចុះឈ្មោះបោះឆ្នោត

ដើម្បីចុះឈ្មោះបោះឆ្នោតបាន ប្រជាពលរដ្ឋទាំងពីរភេទត្រូវ៖

- បង្ហាញខ្លួន និងមាន អ.ខ ឬ ឯ.អ នៅចំពោះមុខ ក.ច.ប ដែលទទួលបន្ទុកជាមន្ត្រីចុះឈ្មោះបោះឆ្នោតក្នុងអំឡុងពេលនៃការចុះឈ្មោះបោះឆ្នោត នៅការិយាល័យចុះឈ្មោះបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ ដែលខ្លួនត្រូវចុះឈ្មោះបោះឆ្នោត
- បំពេញលក្ខខណ្ឌដើម្បីមានឈ្មោះក្នុងបញ្ជីបោះឆ្នោត (ដូចចំណុច ១ ខាងលើ)
- មិនទាន់បានចុះឈ្មោះ ឬបានចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ផ្សេងណាមួយរួចហើយ ឬមិនទាន់បានចុះឈ្មោះនៅកន្លែងណាមួយក្នុងឃុំ សង្កាត់។

## ៣. ឯកសារសម្រាប់ប្រើប្រាស់ក្នុងការសុំចុះឈ្មោះបោះឆ្នោត

ជាគោលការណ៍ ឯកសារសម្រាប់ប្រើប្រាស់ក្នុងការសុំចុះឈ្មោះបោះឆ្នោត គឺអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ដែលនៅមានសុពលភាព (ប្រភេទទី២ និងប្រភេទទី៣)។

### ក. ឯកសារដែលអ្នកសុំចុះឈ្មោះបោះឆ្នោតត្រូវបង្ហាញ ក.ច.ប ដើម្បីសុំចុះឈ្មោះបោះឆ្នោត

| ឯកសារ / ករណី |  ឬ  (អ.ខ) |  (ឯ.អ) |  (សៀវភៅស្នាក់នៅ) |  (សៀវភៅគ្រួសារ) |  (លិខិតបញ្ជាក់ទីលំនៅ) |
|---|---|---|---|---|---|
| មាន អ.ខ និងអាសយដ្ឋានដូច អ.ខ | ✓ | | | | |
| ពុំមាន ឬបាត់ អ.ខ | | ✓(ខ) | | | |
| មាន អ.ខ និងអាសយដ្ឋានផ្សេងពី អ.ខ | ✓ | | ✓ | | |
| | ✓ | | | ✓ | |
| | ✓ | | | | ✓(គ) |

### ខ. សាក្សី និងឯកសារសម្រាប់ការស្នើសុំ ឯ.អ

អ្នកសុំចុះឈ្មោះបោះឆ្នោតត្រូវបង្ហាញខ្លួនដោយផ្ទាល់ចំពោះមុខអាជ្ញាធរឃុំ សង្កាត់ ដែលគាត់ត្រូវចុះឈ្មោះបោះឆ្នោត ដោយនាំមកជាមួយនូវ៖

- សំបុត្រកំណើតច្បាប់ដើម ឬសេចក្ដីចម្លងសំបុត្រកំណើតច្បាប់ដើម ឬសំបុត្របញ្ជាក់កំណើតច្បាប់ដើម ឬសេចក្ដីចម្លងសំបុត្របញ្ជាក់កំណើតច្បាប់ដើម ឬព្រះរាជក្រឹត្យ

ផ្តល់សញ្ជាតិខ្មែរតាមការទាមទារសញ្ជាតិខ្មែររបស់ជនបរទេស ឬព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មដល់ជនបរទេស ឬសាលក្រមស្ថាពររបស់តុលាការបញ្ជាក់ទទួលស្គាល់ថា សាមីខ្លួននោះកើតពីឪពុក ឬម្តាយដែលមានសញ្ជាតិខ្មែរ ឬឯកសារភស្តុតាងផ្លូវការដែលបញ្ជាក់ថា សាមីខ្លួនកើតមកពីឪពុក ឬម្តាយដែលមានសញ្ជាតិខ្មែរ

- រូបថតសាមីខ្លួន ទំហំ ៣×៤ ចំនួន ២សន្លឹក
- សាក្សី ២រូប ដែលមាន៖
  - សិទ្ធិបោះឆ្នោត
  - លំនៅឋាន ឬទីសំណាក់ពិតប្រាកដក្នុងឃុំ សង្កាត់ ទៅជាមួយ។

**គ. សាក្សី និងឯកសារសម្រាប់ការស្នើសុំលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់**

អ្នកសុំចុះឈ្មោះបោះឆ្នោតត្រូវបង្ហាញខ្លួនដោយផ្ទាល់ចំពោះមុខអាជ្ញាធរឃុំ សង្កាត់ដែលគាត់ត្រូវចុះឈ្មោះបោះឆ្នោត ដោយនាំមកជាមួយនូវ៖

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់សាមីខ្លួន
- លិខិតអនុញ្ញាតឱ្យស្នាក់នៅបណ្តោះអាសន្ន (ក៩) ចេញដោយមេប៉ុស្តិ៍នគរបាលរដ្ឋបាលនៃឃុំ សង្កាត់របស់សាមីខ្លួន និង
- សាក្សី ១រូប ដែលមានសិទ្ធិបោះឆ្នោតនៅក្នុងឃុំ សង្កាត់ជាមួយ។

## V. ដំណើរប្រព្រឹត្តទៅនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត

### ១. ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៩

ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៩ មានគោលដៅធានាឱ្យបញ្ជីបោះឆ្នោតមានភាពពេញលេញភាពត្រឹមត្រូវ និងមានបច្ចុប្បន្នភាព ប្រកបដោយសុវត្ថិភាពតាមរយៈ៖




**ចំណាំ៖** រាល់ការស្នើសុំ ត្រូវមានឯកសារផ្លូវការបញ្ជាក់ត្រឹមត្រូវ។

## ២. ជំហានទាំង ៤ នៃការចុះឈ្មោះបោះឆ្នោត

ក.ច.ប ត្រូវអនុវត្តការចុះឈ្មោះបោះឆ្នោតតាមនីតិវិធី ដូចបញ្ជាក់ក្នុងជំហានទាំង៤ ខាងក្រោម៖




## ៣. ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត តាមករណីនីមួយៗ

ក្នុងការចុះឈ្មោះបោះឆ្នោត ការកែតម្រូវទិន្នន័យ ការប្តូរការិយាល័យបោះឆ្នោត និងការលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតនៅតាមឃុំ សង្កាត់ ក.ច.ប ត្រូវអនុវត្តតាមករណីជាក់ស្តែងនីមួយៗ ដូចខាងក្រោម៖

### ក. ករណីពុំមាន អ.ខ ឬមាន អ.ខ ប៉ុន្តែពុំមានលក្ខខណ្ឌគ្រប់គ្រាន់

ក្រោយអនុវត្តជំហានទី១ ឬ/និងជំហានទី២ រួចហើយ ប្រសិនបើពិនិត្យឃើញករណីដូចខាងក្រោម ប្រធាន ក.ច.ប ត្រូវ៖

➢ **ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតពុំមាន អ.ខ**

- បដិសេធការសុំចុះឈ្មោះបោះឆ្នោត ដោយ ទ.១០០៩ ដោយធ្វើការបញ្ជាក់ពីមូលហេតុ និងលក្ខខណ្ឌដែលអ្នកសុំចុះឈ្មោះបោះឆ្នោតមិនបានបំពេញ
- ណែនាំគាត់ ដូចខាងក្រោម៖
  - សូមទៅរាយការណ៍ជាបន្ទាន់ជូនអាជ្ញាធរមានសមត្ថកិច្ច ដើម្បីបំពេញបែបបទផ្តល់ អ.ខ ជូន
  - ស្នើសុំ ឯ.អ ពីអាជ្ញាធរឃុំ សង្កាត់
- ជម្រាបគាត់ថា នៅពេលអ្នកទទួលបាន អ.ខ ឬ ឯ.អ ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត អ្នកត្រូវត្រឡប់មកជួប ក.ច.ប វិញ ដើម្បីសុំចុះឈ្មោះបោះឆ្នោត។

➢ **ករណីអ្នកសុំចុះឈ្មោះមាន អ.ខ ប៉ុន្តែអាសយដ្ឋានក្នុង អ.ខ ផ្សេង**

- បដិសេធការសុំចុះឈ្មោះបោះឆ្នោត ដោយ ទ.១០០៩ ដោយធ្វើការបញ្ជាក់ពីមូលហេតុ និងលក្ខខណ្ឌដែលអ្នកសុំចុះឈ្មោះបោះឆ្នោតមិនបានបំពេញ
- ណែនាំគាត់ ដូចខាងក្រោម៖
  - ទៅយកសៀវភៅស្នាក់នៅច្បាប់ដើម ឬសៀវភៅគ្រួសារច្បាប់ដើម ដែលមានបញ្ជាក់ពីការស្នាក់នៅរបស់សាមីខ្លួនក្នុងឃុំ សង្កាត់ដែលត្រូវសុំចុះឈ្មោះបោះឆ្នោត
  - បើគាត់ពុំមានសៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារច្បាប់ដើមទេ គាត់ត្រូវទៅស្នើសុំលិខិតបញ្ជាក់ទីលំនៅពីអាជ្ញាធរឃុំ សង្កាត់
- ជម្រាបគាត់ថា នៅពេលគាត់យកសៀវភៅស្នាក់នៅច្បាប់ដើម ឬសៀវភៅគ្រួសារច្បាប់ដើមបានហើយ ឬទទួលបានលិខិតបញ្ជាក់ទីលំនៅ គាត់ត្រូវត្រឡប់មកជួប ក.ច.ប វិញ ដើម្បីសុំចុះឈ្មោះបោះឆ្នោត។ ការចុះឈ្មោះបោះឆ្នោតក្នុងករណីនេះ ត្រូវអនុវត្តនីតិវិធី ដូចបញ្ជាក់ក្នុងជំហានទាំង៤ ខាងលើ។

**ខ. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតបានចុះឈ្មោះបោះឆ្នោតរួចហើយ ប៉ុន្តែឈ្មោះ ឬ/និងទិន្នន័យក្នុងបញ្ជីបោះឆ្នោតកត់ត្រាមិនត្រឹមត្រូវ**

❖ **ករណីទី១ អ្នកសុំចុះឈ្មោះបោះឆ្នោតបានចុះឈ្មោះបោះឆ្នោតរួចហើយ ឆ្នាំ២០១៩**

ប្រធាន ក.ច.ប ត្រូវជម្រាបអ្នកសុំកែតម្រូវឱ្យទៅជួបការីកុំព្យូទ័រ ដើម្បីបន្តនីតិវិធីស្វែងរកប្រវត្តិចុះឈ្មោះបោះឆ្នោតរបស់គាត់ ដូចខាងក្រោម៖

➢ **ករណីទិន្នន័យរបស់អ្នកស្នើសុំពុំទាន់ត្រូវបានបញ្ជូនមក គ.ជ.ប**

- **ករណីទិន្នន័យក្នុងកុំព្យូទ័រត្រឹមត្រូវ តែទិន្នន័យក្នុង ទ.១០២២ ខុស**
  - ការីកុំព្យូទ័រទាញយកទិន្នន័យ តាមរយៈស្នាមម្រាមដៃ ឬតាមលេខ អ.ខ ឬ ឯ.អ របស់អ្នកស្នើសុំ

- ចាត់អនុប្រធាន ឱ្យធ្វើការកែតម្រូវទិន្នន័យជូនអ្នកសុំនៅលើ ទ.១០២២ ទាំងពីរផ្នែកឡើងវិញ ដោយឆូតលើទិន្នន័យក្នុង ទ.១០២២ ដែលខុសទាំងពីរផ្នែកនោះ រួចសរសេរទិន្នន័យដែលត្រឹមត្រូវក្បែរនោះ តាមទិន្នន័យក្នុង អ.ខ ឬ ឯ.អ និងចុះហត្ថលេខា បោះត្រា ដើម្បីបញ្ជាក់ថា បានកែតម្រូវឈ្មោះ ឬ/និងទិន្នន័យ តាមការស្នើសុំ។

**- ករណីទិន្នន័យក្នុង ទ.១០២២ ត្រឹមត្រូវ តែទិន្នន័យក្នុងកុំព្យូទ័រខុស**

- ចាត់ការីកុំព្យូទ័រឱ្យ៖
  - ទាញយកទិន្នន័យ តាមរយៈស្នាមម្រាមដៃ ឬតាមលេខ អ.ខ ឬ ឯ.អ របស់អ្នកស្នើសុំ
  - ធ្វើការកែតម្រូវទិន្នន័យ ដោយផ្អែកលើ អ.ខ ឬ ឯ.អ របស់អ្នកស្នើសុំ
  - ជម្រាបអ្នកសុំកែតម្រូវឱ្យផ្ទៀងផ្ទាត់ទិន្នន័យរបស់ខ្លួនដែលបង្ហាញនៅលើម៉ូនីទ័រកុំព្យូទ័រ
  - យកស្នាមម្រាមដៃសាមីខ្លួនបញ្ចូលក្នុងប្រព័ន្ធកុំព្យូទ័រ ដើម្បីបញ្ជាក់ថា បានកែតម្រូវត្រឹមត្រូវ និងសម្រាប់រក្សាទុកទិន្នន័យតាមការស្នើសុំ បន្ទាប់មកធ្វើការរក្សាទុកទិន្នន័យរបស់អ្នកសុំកែតម្រូវក្នុងប្រព័ន្ធកុំព្យូទ័រ។

**- ករណីទិន្នន័យក្នុង ទ.១០២២ ក៏ខុស ហើយទិន្នន័យក្នុងកុំព្យូទ័រក៏ខុស**

- ការីកុំព្យូទ័រទាញយកទិន្នន័យ តាមរយៈស្នាមម្រាមដៃ ឬតាមលេខ អ.ខ ឬ ឯ.អ របស់អ្នកស្នើសុំ
- អនុប្រធានត្រូវ៖
  - ធ្វើការកែតម្រូវទិន្នន័យជូនអ្នកសុំនៅលើ ទ.១០២២ ទាំងពីរផ្នែកឡើងវិញ ដោយឆូតលើទិន្នន័យក្នុង ទ.១០២២ ដែលខុសទាំងពីរផ្នែកនោះ
  - រួចសរសេរទិន្នន័យដែលត្រឹមត្រូវក្បែរនោះ តាមទិន្នន័យក្នុង អ.ខ ឬ ឯ.អ និងចុះហត្ថលេខា បោះត្រា ដើម្បីបញ្ជាក់ថា បានកែតម្រូវឈ្មោះ ឬ/និងទិន្នន័យ តាមការស្នើសុំ។
- **ការកែតម្រូវទិន្នន័យក្នុងកុំព្យូទ័រ ត្រូវ៖**
  - ធ្វើការកែតម្រូវទិន្នន័យ ដោយផ្អែកលើ អ.ខ ឬ ឯ.អ របស់អ្នកស្នើសុំ
  - ជម្រាបអ្នកសុំកែតម្រូវឱ្យផ្ទៀងផ្ទាត់ទិន្នន័យរបស់ខ្លួនដែលបង្ហាញនៅលើម៉ូនីទ័រកុំព្យូទ័រ
  - យកស្នាមម្រាមដៃសាមីខ្លួនបញ្ចូលក្នុងប្រព័ន្ធកុំព្យូទ័រ ដើម្បីបញ្ជាក់ថា បានកែតម្រូវត្រឹមត្រូវ និងសម្រាប់រក្សាទុកទិន្នន័យតាមការស្នើសុំ បន្ទាប់មកធ្វើការរក្សាទុកទិន្នន័យរបស់អ្នកសុំកែតម្រូវក្នុងប្រព័ន្ធកុំព្យូទ័រ។

**ចំណាំ៖** ការកែតម្រូវក្នុងករណីនេះ អាចធ្វើបានលុះត្រាតែទិន្នន័យ ពុំទាន់បានបញ្ជូនទៅ ន.គ.ទ.ប។

➢ **ករណីទិន្នន័យរបស់អ្នកស្នើសុំ ត្រូវបាន ក.ច.ប បញ្ជូនមក គ.ជ.ប**

ករណីនេះ អ្នកស្នើសុំកែតម្រូវអាចសុំផ្ទៀងផ្ទាត់ទិន្នន័យក្នុងប្រព័ន្ធកុំព្យូទ័រជាមួយ ទ.១០២២ ឬ អ.ខ ឬ ឯ.អ បាន ប៉ុន្តែមិនអាចកែតម្រូវទិន្នន័យបានទេ។ បើទិន្នន័យក្នុងប្រព័ន្ធកុំព្យូទ័រមិនត្រឹមត្រូវ ក.ច.ប ត្រូវណែនាំគាត់ឱ្យរង់ចាំប្ដឹងតវ៉ាសុំកែតម្រូវទិន្នន័យនៅក្នុងអំឡុងពេលនៃការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង។

❖ **ករណីទី២ អ្នកសុំចុះឈ្មោះបោះឆ្នោតបានចុះឈ្មោះរួចហើយមុនឆ្នាំ២០១៩**

ប្រធាន ក.ច.ប ត្រូវស្នើសុំឱ្យគាត់បង្ហាញ អ.ខ ឬ ឯ.អ ដែលមានទិន្នន័យត្រឹមត្រូវ និងបង្ហាញ ទ.១០២២ បើមាន។ ប្រសិនបើឯកសារដែលគាត់បង្ហាញត្រឹមត្រូវហើយ ប្រធាន ក.ច.ប ត្រូវចាត់ចែងដូចខាងក្រោម៖

- ចាត់អនុប្រធាន ក.ច.ប ឱ្យបំពេញ ទ.១០២៨ ជូនសាមីអ្នកស្នើសុំ។
- ចាត់ការីកុំព្យូទ័រឱ្យអនុវត្តដូចខាងក្រោម៖
  - យកស្នាមមេដៃរបស់អ្នកស្នើសុំកែតម្រូវ ដើម្បីទាញយកទិន្នន័យមកធ្វើការកែតម្រូវ ឬស្វែងរកទិន្នន័យអ្នកស្នើសុំកែតម្រូវតាមរយៈលេខ អ.ខ ឬ អត្តលេខ ឬនាមត្រកូលនាមខ្លួន (ករណីអ្នកស្នើសុំកែតម្រូវ មិនអាចផ្ដល់ស្នាមមេដៃបាន)
  - កែតម្រូវទិន្នន័យ ដោយផ្អែកលើ អ.ខ ឬ ឯ.អ ដែលត្រឹមត្រូវ
  - ជម្រាបអ្នកសុំកែតម្រូវ ឱ្យផ្ទៀងផ្ទាត់ទិន្នន័យរបស់ខ្លួនដែលបង្ហាញនៅលើម៉ូនីទ័រកុំព្យូទ័រ
- ស្នើអ្នកសុំកែតម្រូវផ្ដល់ស្នាមដៃបញ្ចូលក្នុងប្រព័ន្ធកុំព្យូទ័រ ដើម្បីបញ្ជាក់ថា គាត់ពិតជាបានស្នើសុំកែតម្រូវទិន្នន័យ។
- ប្រគល់បង្កាន់ដៃ ទ.១០២៨ ឱ្យអ្នកស្នើសុំកែតម្រូវ។

**ចំណាំ៖** ការកែតម្រូវទិន្នន័យក្នុងបញ្ជីបោះឆ្នោត នឹងត្រូវធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ឡើងវិញដោយ ន.គ.ទ.ប។

**គ. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមាន អ.ខ ឬ ឯ.អ និងធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយ**

ប្រសិនបើអ្នកសុំចុះឈ្មោះបោះឆ្នោតឆ្លើយថា គាត់ធ្លាប់ចុះឈ្មោះបោះឆ្នោតម្ដងរួចហើយ ប្រធាន ក.ច.ប ត្រូវបន្តសំណួរថា តើអ្នកធ្លាប់ចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ណា? ឆ្នាំណា?

❖ **ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតបានចុះឈ្មោះបោះឆ្នោតរួចហើយ តែបានប្ដូរទីលំនៅក្នុងឃុំ សង្កាត់ដដែល ឬសុំប្ដូរការិយាល័យបោះឆ្នោតក្នុងភូមិជាមួយ**

ប្រធាន ក.ច.ប ត្រូវសុំពិនិត្យមើល អ.ខ បង្កាន់ ទ.១០២២ និងឯកសារភ័ស្តុតាងដែលបញ្ជាក់ទីលំនៅថ្មី នៅក្នុងឃុំ សង្កាត់ ដូចជាសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ទីលំនៅ រួចហើយ ប្រធាន ក.ច.ប ត្រូវ៖

• ចាត់អនុប្រធាន គ.ច.ប ឱ្យ៖

- បំពេញទម្រង់បង្កាន់ដៃ ទ.១០២៨ ចុះហត្ថលេខា សរសេរឈ្មោះ បោះត្រា រួច បោះត្រាបន្ថែមរវាងគល់ទម្រង់ និងបង្កាន់ដៃ
- ឱ្យអ្នកស្នើសុំផ្តិតមេដៃ និងសរសេរឈ្មោះលើ ទ.១០២៨
- ហែកបង្កាន់ដៃ ទ.១០២៨ ប្រគល់ឱ្យការីកុំព្យូទ័រ
- ដកហូតបង្កាន់ដៃ ទ.១០២២ ចាស់ប្រសិនបើមាន កិបភ្ជាប់ជាមួយគល់ ទ.១០២៨
- ណែនាំអ្នកស្នើសុំនោះ ឱ្យទៅជួបការីកុំព្យូទ័រ។

• ចាត់ការីកុំព្យូទ័រឱ្យ៖

- ទាញយកទិន្នន័យរបស់អ្នកស្នើសុំ តាមរយៈស្នាមមេដៃ អត្តលេខ ឬលេខ អ.ខ ឬ ឯ.អ ឬនាមត្រកូល និងនាមខ្លួន
- ផ្ទេរឈ្មោះ និងទិន្នន័យអ្នកស្នើសុំទៅការិយាល័យថ្មីក្នុងភូមិដែលគាត់រស់នៅ ដូចបានកំណត់ក្នុង ទ.១០២៨
- ជម្រាបអ្នកស្នើសុំឱ្យផ្ទៀងផ្ទាត់ទិន្នន័យរបស់ខ្លួននៅលើម៉ូនីទ័រកុំព្យូទ័រ
- ស្នើសុំអ្នកសុំប្តូរការិយាល័យផ្តល់ស្នាមម្រាមដៃបញ្ចូលក្នុងប្រព័ន្ធកុំព្យូទ័រដើម្បី បញ្ជាក់ថា គាត់ពិតជាបានស្នើសុំប្តូរការិយាល័យបោះឆ្នោត
- ប្រគល់បង្កាន់ដៃ ទ.១០២៨ ឱ្យអ្នកស្នើសុំ។

**ឃ.ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតបានចុះឈ្មោះបោះឆ្នោតរួចហើយឆ្នាំ២០១៨ ក្នុងឃុំ សង្កាត់ផ្សេង**

ប្រសិនបើអ្នកសុំចុះឈ្មោះបោះឆ្នោតឆ្លើយថា ធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយ នៅឆ្នាំ២០១៨ ក្នុងឃុំ សង្កាត់ផ្សេង ប្រធាន គ.ច.ប ត្រូវបន្តនីតិវិធីនៃការចុះឈ្មោះ បោះឆ្នោត ដូចខាងក្រោម៖

☛ ពិនិត្យភាពមានសិទ្ធិចុះឈ្មោះបោះឆ្នោតរបស់អ្នកសុំចុះឈ្មោះបោះឆ្នោតដូចខាងក្រោម៖

- ផ្ទៀងផ្ទាត់ អ.ខ ឬ ឯ.អ
- មានអាយុ ១៨ឆ្នាំ ឡើងទៅគិតដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ (កើតមុន ឬ ត្រឹមថ្ងៃទី០១ ខែសីហា ឆ្នាំ២០០១)
- មានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវបោះឆ្នោត។
- ជម្រាបអ្នកសុំចុះឈ្មោះឱ្យទៅជួបអនុប្រធាន គ.ច.ប ហើយអនុប្រធានត្រូវបញ្ជូន អ.ខ ឱ្យការីកុំព្យូទ័រស្វែងរកប្រវត្តិចុះឈ្មោះបោះឆ្នោតមុននឹងបន្តនីតិវិធីចុះឈ្មោះ បោះឆ្នោត។

☛ **ករណីរកពុំឃើញឈ្មោះក្នុងបញ្ជីបោះឆ្នោត**

អនុប្រធាន គ.ច.ប និងការីកុំព្យូទ័រ ត្រូវអនុវត្តការចុះឈ្មោះបោះឆ្នោត ដូចករណី ធម្មតា ដែលមានបញ្ជាក់ក្នុងជំហានទី៣ និងជំហានទី៤ ខាងលើ។

☛ **ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតធ្លាប់បានចុះឈ្មោះបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០១៨**

អនុប្រធាន ក.ច.ប ត្រូវសួរទីលំនៅក្នុងភូមិ ដើម្បីកំណត់បញ្ចូលឈ្មោះក្នុងការិយាល័យបោះឆ្នោត និងត្រូវបំពេញ ទ.១០២២ គ្មានអត្តលេខ សម្រាប់អ្នកផ្លាស់ប្តូរទីលំនៅ ដោយផ្អែកតាមទិន្នន័យក្នុង អ.ខ ឬ ឯ.អ ចុះហត្ថលេខា សរសេរឈ្មោះ និងបោះត្រា។ បន្ទាប់មកត្រូវប្រគល់ អ.ខ ឬ ឯ.អ និងឯកសារពាក់ព័ន្ធទៅការីកុំព្យូទ័រ និងណែនាំអ្នកសុំចុះឈ្មោះនោះឱ្យទៅជួបការីកុំព្យូទ័រ។

☛ **ការីកុំព្យូទ័រ ត្រូវអនុវត្តដូចខាងក្រោម ៖**

- ត្រូវជ្រើសរើសយកឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោត
- ជូតសម្អាតមេដៃអ្នកស្នើសុំ បន្ទាប់មកធ្វើតេស្តស្នាមមេដៃទាំងសងខាង
- ថត អ.ខ ឬ ឯ.អ
- ជ្រើសរើសប្រវត្តិចុះឈ្មោះបោះឆ្នោត (យកពាក្យ ផ្ទេរចូលពីឃុំ សង្កាត់ផ្សេង)
- ស្វែងរកឈ្មោះ និងទិន្នន័យរបស់អ្នកសុំចុះឈ្មោះតាមអត្តលេខ លេខ អ.ខ ឬ ឯ.អ ឬនាមត្រកូល និងនាមខ្លួន
- ត្រូវធ្វើការផ្ទេរទិន្នន័យមួយចំនួនដែលរួមមាន អត្តលេខ លេខ អ.ខ ឬ ឯ.អ នាមត្រកូល និងនាមខ្លួន ភេទ ថ្ងៃ ខែ ឆ្នាំកំណើត
- បញ្ចូលអាសយដ្ឋានអ្នកសុំចុះឈ្មោះបោះឆ្នោត ដោយផ្អែកតាម អ.ខ ឬ ឯ.អ ឬ/និងឯកសារបញ្ជាក់ពីលំនៅឋាន ឬទីសំណាក់
- បំពេញភូមិឧបសម្ព័ន្ធ (ប្រសិនបើមាន)
- ជ្រើសរើសស្ថានភាពពិការភាពអ្នកចុះឈ្មោះបោះឆ្នោត (ប្រសិនបើមាន)
- ថតរូបចំពីមុខ
- ជួយកាន់មេដៃអ្នកសុំចុះឈ្មោះបោះឆ្នោតដាក់លើម៉ាស៊ីនស្កែន ដើម្បីយកស្នាមម្រាមដៃសាមីខ្លួនទាំងសងខាង ឆ្វេងចំនួន៤ដង និងស្តាំចំនួន ៤ដង បញ្ចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រ ដោយត្រូវយកស្នាមម្រាមដៃឆ្វេងមុន។
- ថតឯកសារបញ្ជាក់ពីលំនៅឋាន ឬទីសំណាក់
- ជម្រាបអ្នកសុំចុះឈ្មោះបោះឆ្នោតឱ្យគាត់ផ្ទៀងផ្ទាត់ឈ្មោះ និងទិន្នន័យរបស់ខ្លួនដែលបានបង្ហាញនៅលើម៉ូនីទ័រកុំព្យូទ័រ
- ត្រូវចុចលើប្រអប់ ត្រូវរក្សាទុក (Save) ទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោតទៅក្នុងប្រព័ន្ធកុំព្យូទ័រ និងចុចលើពាក្យយល់ព្រម។
- ប្រគល់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) និង អ.ខ ឬ ឯ.អ ឬឯកសារបញ្ជាក់ពីលំនៅឋាន ឬទីសំណាក់ ជូនអ្នកសុំចុះឈ្មោះបោះឆ្នោត។

ង. ករណីអ្នកសុំចុះឈ្មោះបានចុះឈ្មោះបោះឆ្នោតរួចហើយនៅឃុំ សង្កាត់ផ្សេងក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត

ប្រសិនបើអ្នកសុំចុះឈ្មោះបោះឆ្នោតឆ្លើយថា គាត់ធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយនៅឃុំ សង្កាត់ផ្សេងក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ប្រធាន ក.ច.ប ត្រូវបន្តអនុវត្តនីតិវិធីចុះឈ្មោះបោះឆ្នោត ដូចមានបញ្ជាក់ក្នុងជំហានទាំង៤ នៃការចុះឈ្មោះបោះឆ្នោត ដោយឱ្យអនុប្រធាន ក.ច.ប គូសធិកសម្គាល់ក្នុង ទ.១០២២ បន្ថែម ដើម្បីបញ្ជាក់ពីករណីនេះ និងដកហូត ទ.១០២២ ចាស់ (បើមាន) កិបភ្ជាប់នឹងគល់ ទ.១០២២ ថ្មី។

ច. ករណីអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត បានទទួលមរណភាពក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត

ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ប្រសិនបើមានរបាយការណ៍អំពីអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតបានទទួលមរណភាព មានឯកសារសម្អាងត្រឹមត្រូវ និងច្បាស់លាស់ ប្រធាន ក.ច.ប ត្រូវ៖

- ពិនិត្យឯកសារពាក់ព័ន្ធ
- ចាត់អនុប្រធានឱ្យបំពេញ ទ.១០២៥ និងរាយការណ៍ជូន កបឃ.ស ដើម្បីអនុវត្តនីតិវិធីស្រង់ឈ្មោះដាក់ក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត ដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត។

៤. ការពិនិត្យ និងសម្រេចរបស់ ក.ច.ប លើរបាយការណ៍ស្ដីពីការស្រង់ឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត

បន្ទាប់ពីទទួលបានរបាយការណ៍ស្ដីពីការស្រង់ឈ្មោះអ្នកបោះឆ្នោត ដែលបានទទួលមរណភាព ឬត្រូវបានដកហូតជាបណ្ដោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬបានផ្លាស់ លំនៅ-ឋាន ឬទីសំណាក់ទៅឃុំ សង្កាត់ផ្សេង និងមានឯកសារសម្អាងត្រឹមត្រូវ និងច្បាស់លាស់ ដែលទទួលបានពី លធ.ខប ឬ កបឃ.ស ក.ច.ប ត្រូវធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់តាមករណីនីមួយៗ ដោយផ្អែកលើឯកសារសម្អាង និងទិន្នន័យក្នុងប្រព័ន្ធកុំព្យូទ័រ ប្រធាន និងអនុប្រធាន ក.ច.ប ត្រូវ ៖

- ធ្វើការពិនិត្យលើបញ្ជីឈ្មោះអ្នកបោះឆ្នោត ដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតជាមួយនឹងឯកសារសម្អាងឱ្យបានច្បាស់លាស់ តាមករណីនីមួយៗ និងទិន្នន័យមួយចំនួនក្នុងបញ្ជីបោះឆ្នោតចុងក្រោយ ដូចជាលេខ អ.ខ ឬ ឯ.អ នាមត្រកូល នាមខ្លួន ភេទ និងថ្ងៃខែឆ្នាំកំណើតជាដើម។
- ចាត់ការីកុំព្យូទ័រឱ្យធ្វើការផ្ទៀងផ្ទាត់បញ្ជីនេះជាមួយទិន្នន័យក្នុងប្រព័ន្ធកុំព្យូទ័របន្ថែមទៀត។
- បន្ទាប់មក ប្រធាន និងអនុប្រធាន ក.ច.ប ត្រូវសម្រេចលើបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត ហើយចាត់ឱ្យការីកុំព្យូទ័រធ្វើការស្នើសុំលុបឈ្មោះអ្នកទាំងនោះ តាមកម្មវិធីកុំព្យូទ័រដែលបានកំណត់មក គ.ជ.ប ដោយភ្ជាប់មកជាមួយនូវឯកសារសម្អាង។

## VI. គំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងក្នុងដំណាក់កាលនៃការចុះឈ្មោះបោះឆ្នោត



## VII. ការប្រើប្រាស់ទម្រង់បែបបទ

<u>**ទ.១០០៩**</u> គឺជាសេចក្តីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត ដែលប្រធាន ក.ច.ប ប្រើប្រាស់ក្នុងការបដិសេធការសុំចុះឈ្មោះបោះឆ្នោត ដែលមិនបានបំពេញតាមលក្ខខណ្ឌកំណត់។ ទ.១០០៩ បំពេញចំនួន ១ច្បាប់ ហើយចុះហត្ថលេខា បោះត្រានៅលើផ្នែកទី១ និងផ្នែកទី២ និងចំកណ្តាលកន្លែងហែកផ្តាច់ បន្ទាប់មកហែកផ្នែកទី២ ប្រគល់ឱ្យអ្នកសុំចុះឈ្មោះ និងផ្នែកទី១ ត្រូវរក្សាទុកដើម្បីដាក់ក្នុងស្បោង «ខ»។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

**សេចក្តីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត (ទ.១០០៩)**

NºXXXXXXXX

**១. លក្ខណៈសម្គាល់នៃឃុំ សង្កាត់**

| | | | | | | | |
|---|---|---|---|---|---|---|---|
| ឈ្មោះ និងលេខកូដឃុំ សង្កាត់ | | | | ឈ្មោះ និងលេខកូដរាជធានី ខេត្ត | | | |
| ឈ្មោះភូមិ | | | | កាលបរិច្ឆេទនៃការសុំចុះឈ្មោះបោះឆ្នោត | / / | | |

**២. អត្តសញ្ញាណនៃអ្នកសុំចុះឈ្មោះបោះឆ្នោត**

| | | | | | |
|---|---|---|---|---|---|
| នាមត្រកូលនិងនាមខ្លួន | | ភេទ | | ថ្ងៃខែឆ្នាំកំណើត | / / |
| លំនៅឋាន ឬទីសំណាក់ : ផ្ទះលេខ | ផ្លូវ | ភូមិ | | ឃុំ សង្កាត់ | |

**៣. មូលហេតុនៃការបដិសេធការសុំចុះឈ្មោះបោះឆ្នោត**

☐ - គ្មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (សាមីខ្លួនត្រូវទៅជួបអាជ្ញាធរឃុំ សង្កាត់ ដើម្បីបំពេញបែបបទស្នើសុំឯកសារបញ្ជាក់អត្តសញ្ញាណ)

☐ - មិនគ្រប់អាយុបោះឆ្នោត

☐ - គ្មានឯកសារបញ្ជាក់លំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ (សាមីខ្លួនត្រូវទៅជួបអាជ្ញាធរឃុំ សង្កាត់ សុំលិខិតបញ្ជាក់ទីលំនៅ)

☐ - ស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ឬត្រូវបានដកសិទ្ធិបោះឆ្នោត ឬ ☐ ជនវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាលទូទៅ ដោយមានលិខិតបញ្ជាក់ពី ក្រសួង ស្ថាប័នមានសមត្ថកិច្ច

☐ - ការសុំចុះឈ្មោះបោះឆ្នោតក្រោយរយៈពេលកំណត់

**៤. សម្រាប់គ្រូមចុះឈ្មោះបោះឆ្នោត**

កាលបរិច្ឆេទ៖ ........./........../............ ហត្ថលេខាប្រធាន ក.ច.ប ................................ ត្រាការិយាល័យចុះឈ្មោះបោះឆ្នោត

---


គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

**សេចក្តីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត (ទ.១០០៩)**

NºXXXXXXXX

**១. លក្ខណៈសម្គាល់នៃឃុំ សង្កាត់**

| | | | | | | | |
|---|---|---|---|---|---|---|---|
| ឈ្មោះ និងលេខកូដឃុំ សង្កាត់ | | | | ឈ្មោះ និងលេខកូដរាជធានី ខេត្ត | | | |
| ឈ្មោះភូមិ | | | | កាលបរិច្ឆេទនៃការសុំចុះឈ្មោះបោះឆ្នោត | / / | | |

**២. អត្តសញ្ញាណនៃអ្នកសុំចុះឈ្មោះបោះឆ្នោត**

| | | | | | |
|---|---|---|---|---|---|
| នាមត្រកូលនិងនាមខ្លួន | | ភេទ | | ថ្ងៃខែឆ្នាំកំណើត | / / |
| លំនៅឋាន ឬទីសំណាក់ : ផ្ទះលេខ | ផ្លូវ | ភូមិ | | ឃុំ សង្កាត់ | |

**៣. មូលហេតុនៃការបដិសេធការសុំចុះឈ្មោះបោះឆ្នោត**

☐ - គ្មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (សាមីខ្លួនត្រូវទៅជួបអាជ្ញាធរឃុំ សង្កាត់ ដើម្បីបំពេញបែបបទស្នើសុំឯកសារបញ្ជាក់អត្តសញ្ញាណ)

☐ - មិនគ្រប់អាយុបោះឆ្នោត

☐ - គ្មានឯកសារបញ្ជាក់លំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ (សាមីខ្លួនត្រូវទៅជួបអាជ្ញាធរឃុំ សង្កាត់ សុំលិខិតបញ្ជាក់ទីលំនៅ)

☐ - ស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ឬត្រូវបានដកសិទ្ធិបោះឆ្នោត ឬ ☐ ជនវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាលទូទៅ ដោយមានលិខិតបញ្ជាក់ពី ក្រសួង ស្ថាប័នមានសមត្ថកិច្ច

☐ - ការសុំចុះឈ្មោះបោះឆ្នោតក្រោយរយៈពេលកំណត់

**៤. សម្រាប់គ្រូមចុះឈ្មោះបោះឆ្នោត**

កាលបរិច្ឆេទ៖ ........./........../............ ហត្ថលេខាប្រធាន ក.ច.ប ................................ ត្រាការិយាល័យចុះឈ្មោះបោះឆ្នោត


ទម្រង់បែបបទ ១០០៩ សម្រាប់បំពេញដោយ ក.ច.ប

- **ទ.១០១១** គឺជារបាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត តាមការិយាល័យបោះឆ្នោតដែល ក.ច.ប ត្រូវបំពេញបន្ទាប់ពីបានបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**របាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១)**

**១. លក្ខណៈសម្គាល់នៃការិយាល័យបោះឆ្នោត**

| | | | | | |
|---|---|---|---|---|---|
| ឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោត | | | | | |
| ឈ្មោះ និងលេខកូដឃុំ សង្កាត់ | | | | | |
| ឈ្មោះ និងលេខកូដរាជធានី ខេត្ត | | | | | |

**២. របាយការណ៍ស្តីពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត**

| ចាប់ផ្តើមពីថ្ងៃទី / / ដល់ថ្ងៃទី / / | ចំនួនសរុប |
|---|---|
| ក- ចំនួនឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០១៨សរុប | |
| ខ- ចំនួនគល់បង្កាន់ដៃ ទ.១០២២ មានអត្តលេខសរុប (ចុះឈ្មោះថ្មី) | |
| គ- ចំនួនគល់បង្កាន់ដៃ ទ.១០២២ គ្មានអត្តលេខសរុប (ផ្ទេរចូលពីក្រៅឃុំ សង្កាត់) | |
| ឃ- ចំនួនគល់បង្កាន់ដៃ ទ.១០២៨ ប្តូរការិ. "ប្តូរចូល" ក្នុងឃុំ សង្កាត់សរុប | |
| ង- ចំនួនលុបឈ្មោះពីបញ្ជីបោះឆ្នោត (ស្លាប់ ដកសិទ្ធិ ផ្លាស់ចេញ ផ្ទេរចេញ និងប្តូរការិ. "ប្តូរចេញ" ក្នុងឃុំ សង្កាត់) | |
| ច- ចំនួនសរុបអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតដែលបានពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៩ | |

សម្គាល់ : - ការផ្ទៀងផ្ទាត់ចំនួនក្នុងបញ្ជីតាមរូបមន្ត : ច = ( ក + ខ + គ + ឃ ) – ង

- ចំពោះការិយាល័យបោះឆ្នោតទើបបង្កើតថ្មី គ្មានចំនួនឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០១៨ ទេ ( ក = 0 )

| | |
|---|---|
| ឆ- ចំនួនគល់បង្កាន់ដៃ ទ.១០២៨ កែតម្រូវឈ្មោះ និងទិន្នន័យសរុប | |

កាលបរិច្ឆេទ៖ ............./............./.............

**ប្រធានក្រុមចុះឈ្មោះបោះឆ្នោត**

ត្រាការិ.ចុះឈ្មោះបោះឆ្នោត

ឈ្មោះ.......................... លេខទូរស័ព្ទ..........................

**៤. សាក្សី : ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ( អាចសរសេរបន្ថែមខាងខ្នង )**

| ល.រ | នាមត្រកូល និងនាមខ្លួន | គណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ | ហត្ថលេខា | ល.រ | នាមត្រកូល និងនាមខ្លួន | គណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ | ហត្ថលេខា |
|---|---|---|---|---|---|---|---|
| ១ | | | | ៦ | | | |
| ២ | | | | ៧ | | | |
| ៣ | | | | ៨ | | | |
| ៤ | | | | ៩ | | | |
| ៥ | | | | ១០ | | | |

***កំណត់សម្គាល់ :*** *ក.ច.ប ត្រូវបំពេញទម្រង់បែបបទនេះចំនួន ៤ ច្បាប់ : ច្រកស្រោមសំបុត្រដាក់ក្នុងកញ្ចប់ "ក" ១ច្បាប់ កិបភ្ជាប់ទៅនឹងផ្នែកខាងក្រៅនៃកញ្ចប់ "ក" ចំនួន ២ ច្បាប់ និងរក្សាទុកជាឯកសាររបស់ឃុំ សង្កាត់ ១ ច្បាប់ ។*

ទម្រង់បែបបទ ១០១១ សម្រាប់បំពេញដោយ ក.ច.ប

ប្រសិនបើគ្មានបណ្តឹងតវ៉ាដាក់នៅ កបឃ.ស ក្នុងរយៈពេល ៣ថ្ងៃ បន្ទាប់ពីថ្ងៃបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតទេ ក.ច.ប ត្រូវធ្វើរបាយការណ៍ ទ.១០១១ នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៩។

ប្រសិនបើមានបណ្ដឹងតវ៉ាមួយ ឬច្រើន ត្រូវបានដាក់នៅ កបឃ.ស ក.ច.ប ត្រូវធ្វើរបាយការណ៍ ទ.១០១១ តាមការិយាល័យពាក់ព័ន្ធក្នុងឃុំ សង្កាត់ បន្ទាប់ពី កបឃ.ស បានសម្រេចដោះស្រាយបណ្ដឹងចប់ ក.ច.ប ត្រូវធ្វើរបាយការណ៍នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៩។ ទ.១០១១ ប្រើប្រាស់ដូចខាងក្រោម៖

*ទ.១០១១ ចំនួន ៤ច្បាប់*
- *១ ច្បាប់ ច្រកស្រោមសំបុត្រ សម្រាប់ដាក់ក្នុងកញ្ចប់ «ក»*
- *២ ច្បាប់ តិបភ្ជាប់នៅផ្នែកខាងក្រៅកញ្ចប់ «ក»*
- *១ ច្បាប់ ក.ច.ប រក្សាទុកជាឯកសារ*

☛ **<u>ទ.១០១២</u>** គឺជារបាយការណ៍សរុបស្ដីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំសង្កាត់ ដែល ក.ច.ប ត្រូវបំពេញ ទ.១០១២ ចំនួន ៣ច្បាប់ ឱ្យរួចរាល់នៅមុនពេលវេចខ្ចប់កញ្ចប់ «ក» ដាក់ក្នុងស្បោង «ខ»។ ទ.១០១២ ប្រើប្រាស់ ដូចខាងក្រោម៖

*ទ.១០១២ ចំនួន ៣ច្បាប់*
- *២ច្បាប់ ច្រកស្រោមសំបុត្រសម្រាប់ដាក់ក្នុងស្បោង«ខ»(ផ្ញើជូនគ.ជ.បចំនួន១ច្បាប់ និងលធ.ឧប ចំនួន១ច្បាប់)*
- *១ច្បាប់ ក.ច.ប រក្សាទុកជាឯកសារ ក្រោយមកទុកជាឯកសារនៅសាលាឃុំ សង្កាត់*

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**របាយការណ៍សរុបស្ដីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១០១២)**

**១. លក្ខណៈសម្គាល់នៃឃុំ សង្កាត់**

| | | | | |
|---|---|---|---|---|
| ឈ្មោះ និងលេខកូដឃុំ សង្កាត់ | | | | |
| ឈ្មោះ និងលេខកូដរាជធានី ខេត្ត | | | | |
| ចំនួនការិយាល័យបោះឆ្នោតសរុប (មុនពេលចុះឈ្មោះ) | | ចំនួនការិយាល័យបង្កើតថ្មី | | |
| ចំនួនការិយាល័យមិនបានប្រើ | | ចំនួនការិយាល័យបានប្រើសរុប | | |

**២. ការិយាល័យចុះឈ្មោះបោះឆ្នោត និងសមាសភាពមន្ត្រីចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់**

ក- ការិយាល័យចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់មាន......................កន្លែង (**ឈ្មោះភូមិអាចសរសេរបន្ថែមខាងខ្នង**)

| | | | |
|---|---|---|---|
| ១-សាលាឃុំ សង្កាត់ | ២-ភូមិ | ៣-ភូមិ | ៤-ភូមិ |
| ៥-ភូមិ | ៦-ភូមិ | ៧-ភូមិ | ៨-ភូមិ |

ខ-សមាសភាពក្រុមចុះឈ្មោះបោះឆ្នោតមានចំនួន................នាក់

| | | | | | |
|---|---|---|---|---|---|
| ប្រធាន | | លេខទូរស័ព្ទ : | អនុប្រធាន | | លេខទូរស័ព្ទ : |
| សមាជិក | | សមាជិក | | សមាជិក | |

**៣. របាយការណ៍ស្ដីពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់**

| ចាប់ផ្ដើមពីថ្ងៃទី / / ដល់ថ្ងៃទី / / | ចំនួនសរុប |
|---|---|
| ក- ចំនួនឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០១៨ គ្រប់ការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់សរុប | |
| ខ- ចំនួនគល់បង្កាន់ដៃ ទ.១០២២ មានអត្តលេខ (ចុះឈ្មោះថ្មី) គ្រប់ការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់សរុប | |
| គ- ចំនួនគល់បង្កាន់ដៃ ទ.១០២២ គ្មានអត្តលេខ (ផ្ទេរចូលពីក្រៅឃុំ សង្កាត់) គ្រប់ការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់សរុប | |
| ឃ- ចំនួនគល់បង្កាន់ដៃ ទ.១០២៨ ប្ដូរការិ. "ប្ដូរចូល" ក្នុងឃុំ សង្កាត់គ្រប់ការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់សរុប | |
| ង- ចំនួនលុបឈ្មោះពីបញ្ជីបោះឆ្នោត (ស្លាប់ ដកសិទ្ធិ ផ្លាស់ចេញ ផ្ទេរចេញ និងប្ដូរការិ. "ប្ដូរចេញ" ក្នុងឃុំ សង្កាត់) គ្រប់ការិ.បោះឆ្នោតក្នុងឃុំ សង្កាត់សរុប | |
| ច- ចំនួនអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតដែលបានពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៩ គ្រប់ការិ.បោះឆ្នោតក្នុងឃុំ សង្កាត់សរុប | |

**សម្គាល់ :** - ការផ្ទៀងផ្ទាត់ចំនួនក្នុងបញ្ជីតាមរូបមន្ត : ច = ( ក + ខ + គ + ឃ ) – ង

| | |
|---|---|
| ឆ- ចំនួនគល់បង្កាន់ដៃ ទ.១០២៨ កែតម្រូវឈ្មោះ និងទិន្នន័យគ្រប់ការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់សរុប | |
| ជ- ចំនួនសេចក្ដីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោតដែលត្រូវបានចេញក្នុងឃុំ សង្កាត់សរុប | |
| ឈ-ចំនួនទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោតដែលបានទទួលសម្រាប់ឃុំ សង្កាត់សរុប | |
| ញ- ចំនួនទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោតខូចដែលត្រូវបានគូសបដិសេធចោលសរុប | |
| ដ- ចំនួនទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោតនៅសល់មិនទាន់ប្រើ គិតទាំងសន្លឹកនៅសល់ក្នុងសៀវភៅបានប្រើសរុប | |

**៤. ហេតុការណ៍សំខាន់ៗដែលកើតមានក្នុងរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត (អាចសរសេរបន្ថែមខាងខ្នង)**

..........................................................................................

**៥. សម្រាប់ក្រុមចុះឈ្មោះបោះឆ្នោត**

កាលបរិច្ឆេទ៖ ........../........../.......... ហត្ថលេខាប្រធាន ក.ច.ប .............................. ត្រាការិយាល័យចុះឈ្មោះបោះឆ្នោត

អនុប្រធាន ក.ច.ប .............................. សមាជិក ក.ច.ប ..............................

សមាជិក ក.ច.ប .............................. សមាជិក ក.ច.ប ..............................

**កំណត់សម្គាល់ :** *ទម្រង់បែបបទនេះត្រូវបំពេញចំនួន ៣ច្បាប់ : ២ច្បាប់ច្រកក្នុងស្រោមសំបុត្រដាក់ក្នុងស្បោង "ខ" ក្នុងនោះផ្ញើជូន លធ.ឧប ១ច្បាប់ ផ្ញើជូននាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត ១ច្បាប់ និងរក្សាទុក១ច្បាប់ ជាឯកសាររបស់ឃុំ សង្កាត់ ។*

ទម្រង់បែបបទ ១០១២ សម្រាប់បំពេញដោយ ក.ច.ប

- **<u>ទ.១០១៣</u>** គឺជាលិខិតបញ្ជាក់ការវេចខ្ចប់សម្ភារ ឯកសារ និងការបញ្ជូនស្បោង «ខ» ដោយក្រុមចុះឈ្មោះ ដែល ក.ច.ប ត្រូវបំពេញ ទ.១០១៣ ចំនួន ៤ច្បាប់ ឱ្យរួចរាល់នៅមុនពេលវេចខ្ចប់ស្បោង «ខ»។ ទ.១០១៣ ប្រើប្រាស់ដូចខាងក្រោម ៖

*ទ.១០១៣ ចំនួន ៤ច្បាប់*
- *២ច្បាប់ ច្រកស្រោមសំបុត្ររួចដាក់ក្នុងស្បោង «ខ»*
- *១ច្បាប់ ដាក់ហោប៉ៅខាងក្រៅនៃស្បោង «ខ»*
- *១ច្បាប់ ក.ច.ប ទុកសម្រាប់ប្រគល់ ទទួលនៅ លធ.ឃប (ក្រោយមកទុកជាឯកសារឃុំ សង្កាត់)*

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**លិខិតបញ្ជាក់ការវេចខ្ចប់សម្ភារឯកសារចុះឈ្មោះបោះឆ្នោត និងការបញ្ជូនស្បោង " ខ " ដោយក្រុមចុះឈ្មោះ (ទ.១០១៣)**

**១. លក្ខណៈសម្គាល់នៃឃុំ សង្កាត់**

| ឈ្មោះ និងលេខកូដឃុំ សង្កាត់ | | | | | ឈ្មោះ និងលេខកូដរាជធានី ខេត្ត | | | |
|---|---|---|---|---|---|---|---|---|

**២. សម្ភារឯកសារចុះឈ្មោះបោះឆ្នោត ដែលត្រូវបានវេចខ្ចប់ក្នុងស្បោង " ខ " សម្រាប់បញ្ជូនទៅ លធ.ឃប**

ក-ក្រុមចុះឈ្មោះបោះឆ្នោតបានវេចខ្ចប់ដាក់ក្នុងស្បោង " ខ " ទី១ នូវ៖

☐ - កញ្ចប់ដាក់គល់សន្លឹកបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ( ទ.១០២២ មានអត្តលេខ និងគ្មានអត្តលេខ ) និងទម្រង់បង្កាន់ដៃនៅសល់ក្នុងសៀវភៅដែលបានប្រើហើយ

☐ - កញ្ចប់ដាក់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះដែលនៅសល់មិនទាន់ប្រើ ដែលត្រូវផ្ញើជូន លធ.ឃប ដើម្បីរក្សាទុក

☐ - ស្រោមសំបុត្រដាក់គល់បង្កាន់ដៃទទួលការកែតម្រូវទិន្នន័យ ឬ/និងការប្តូរការិយាល័យក្នុងឃុំ សង្កាត់ ( ទ.១០២៨ )

☐ - ស្រោមសំបុត្រដាក់របាយការណ៍សរុបស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១០១២) ដែលត្រូវផ្ញើជូន លធ.ឃប ១ច្បាប់ និងផ្ញើជូន គ.ជ.ប ១ច្បាប់

☐ - ស្រោមសំបុត្រដាក់រាល់សេចក្តីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត ( ទ.១០០៩ )

☐ - ស្រោមសំបុត្រដាក់លិខិតបញ្ជាក់ការវេចខ្ចប់សម្ភារឯកសារចុះឈ្មោះបោះឆ្នោត និងការបញ្ជូនស្បោង " ខ " ( ទ.១០១៣) ចំនួន ២ ច្បាប់

ខ-ក្រុមចុះឈ្មោះបានវេចខ្ចប់ដាក់ក្នុងស្បោង " ខ " ទី២ ឬបន្តបន្ទាប់ នូវ៖

☐ - កញ្ចប់ " ក " ចំនួន............ កញ្ចប់ ដែលមានកំណត់សម្គាល់ដោយលេខកូដការិយាល័យបោះឆ្នោត : ( អាចសរសេរបន្ថែមខាងខ្នង)

☐ - ស្រោមសំបុត្រដាក់លិខិតបញ្ជាក់ការវេចខ្ចប់សម្ភារឯកសារចុះឈ្មោះបោះឆ្នោត និងការបញ្ជូនស្បោង " ខ " ( ទ.១០១៣) ចំនួន ២ ច្បាប់ ។

**៣. សម្ភារដែលបានផ្គត់ផ្គង់បន្ថែមក្នុងរយៈពេលចុះឈ្មោះ** :..........................................................................................

..........................................................................................................................

**៤. សម្រាប់ក្រុមចុះឈ្មោះបោះឆ្នោត**

បានវេចខ្ចប់កញ្ចប់សម្ភារឯកសារ និងរាល់ស្រោមសំបុត្រ ឬ/និងកញ្ចប់ " ក " ដូចបានបញ្ជាក់ខាងលើទៅក្នុងស្បោង " ខ " និងបានបញ្ជូនស្បោង " ខ " នេះ ។

កាលបរិច្ឆេទ៖ ........./.........../........... ហត្ថលេខាប្រធាន ក.ច.ប ................................. ត្រាការិយាល័យចុះឈ្មោះបោះឆ្នោត

**៥. សម្រាប់លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ឃប)**

បានទទួលស្បោង " ខ " ដែលមានដាក់កញ្ចប់សម្ភារឯកសារ និងរាល់ស្រោមសំបុត្រ ឬ/និងកញ្ចប់ " ក " ដូចបានបញ្ជាក់ខាងលើគ្រប់ចំនួន ហើយបានពិនិត្យវេចខ្ចប់ឡើងវិញ និងផ្ទុកក្នុងស្បោង " គ " ចំនួន........................ ស្បោងសម្រាប់បញ្ជូនទៅ គ.ជ.ប ។

**ភាពមិនប្រក្រតី (ប្រសិនបើមាន)** :..........................................................................................

កាលបរិច្ឆេទ៖ ........./.........../........... ហត្ថលេខាប្រធាន លធ.ឃប ........................... ត្រា

**៦. សម្រាប់នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត**

បានទទួលស្បោង " ខ " មានដាក់កញ្ចប់សម្ភារឯកសារ និងរាល់ស្រោមសំបុត្រ ឬ/និងកញ្ចប់ " ក " ដូចបានបញ្ជាក់ខាងលើដែលផ្ទុកក្នុងស្បោង " គ " និងដែលប្រគល់ឱ្យដោយមន្ត្រី លធ.ឃប ។

កាលបរិច្ឆេទ៖ ........./.........../........... ហត្ថលេខាមន្ត្រីទទួលសម្ភារឯកសារ .................................

